# សហគមន៍ខ្មែរកម្ពុជាក្រោម - ទ្វីបអាមេរិកខាងជើង

**KHMER KAMPUCHEA KROM COMMUNITY-NORTH AMERICA**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM- L'AMÉRIQUE DU NORD**

## សូត្រទុក្ខថា

## លោក គិម ប.ម. សកល

## នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោមប្រចាំទ្វីបអាមេរិកខាងជើង

## ចូលរួមមរណទុក្ខរបស់អ្នកស្រី ថាច់ ធី សាង

-សូមនមស្សការចំពោះប្រជុំបីនៃព្រះត្រៃរតន៍ ដោយសេចក្តីគោរព

-សូមគោរពនិងថ្វាយបង្គំព្រះវិញ្ញាណក្ខ័ន្ធព្រះវិរសមណៈ ព្រះវិញ្ញាណក្ខ័ន្ធវិរព្រះមហាក្សត្រ វិញ្ញាណក្ខ័ន្ធវិរបុរស វិរនារី និងប្រជាពលរដ្ឋស្នេហាជាតិទាំងអស់ជាទីសក្ការៈ

-សូមគោរពវិញ្ញាណក្ខ័ន្ធសពអ្នកស្រី ថាច់ ធី សាង ដោយសេចក្តីសោកស្តាយ

-សូមក្រាបថ្វាយបង្គំព្រះគ្រូចៅអធិការវត្ត

-សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ

-សូមគោរពលោក សឺន ថាន់ ឡឹប និងក្រុមគ្រួសារសព

-សូមគោរពលោក សឺន ហ. ហេនរី ប្រធានកិត្តិយសសហគមន៍ខ្មែរកម្ពុជាក្រោមប្រចាំទ្វីបអាមេរិកខាងជើង

-សូមគោរពលោក ថាច់ ឃ្លាំង ប្រធានស្តីទីក្រុមប្រឹក្សាភិបាសហគមន៍ខ្មែរកម្ពុជាក្រោមប្រចាំទ្វីបអាមេរិកខាងជើង

-សូមគោរពលោក លោកស្រី ពុទ្ធបរិស័ទ និងបងប្អូនជនរួមជាតិជាទីស្នេហា

សហគមន៍ខ្មែរកម្ពុជាក្រោមប្រចាំទ្វីបអាមេរិកខាងជើង សមាជិក សមាជិកា និងខ្ញុំបាទមានសេចក្តីសោកស្តាយ ដោយបានទទួលពត៌មានដ៏សង្វេគយ៉ាងក្រៃលែង ក្នុងការទទួលមរណភាពរបស់**អ្នកស្រី ថាច់ ធី សាង** ហៅ គឹម ឡៀង ដែលជាភរិយា មាតា និងជីដូន របស់លោក សឺន ថាន់ ឡឹប បុត្រា-បុត្រី និងចៅៗលោក នៅថ្ងៃសុក្រ ១៣ រោច ខែ ផល្គុន ឆ្នាំច អដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី ១៦ ខែ មីនា គ.ស.២០០៧ នៅរដ្ឋនូជើស៊ី សហរដ្ឋអាមេរិក ។

មរណភាពរបស់**អ្នកស្រី ថាច់ ធី សាង** គឺជាការបាត់បង់ស្រ្តីខ្មែរកម្ពុជាក្រោមដ៏សំខាន់មួយរូបនៅក្នុងគ្រួសាររបស់លោក និងការតស៊ូមតិ ដើម្បីជាតិមាតុភូមិ អត្តសញ្ញាណ សិទ្ធិសេរីភាពជំនឿសាសនា សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យជូនប្រជាជាតិ ប្រជារាស្ត្រខ្មែរ និងសាសនា ។

យើងខ្ញុំ និងខ្ញុំបាទ សូមគោរពវិញ្ញាណក្ខ័ន្ធអ្នកស្រី ថាច់ ធី សាង ។ សូមវិញ្ញាណក្ខ័ន្ធអ្នកស្រី ថាច់ ធី សាង ទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ និងសូមអរគុណ។

ទីក្រុងឡូវែល សហរដ្ឋអាមេរិក ថ្ងៃទី១៨ ខែមីនា គ.ស.២០០៧

---

Website: www.khmerkromngo.org
Mailing address in the United States & Canada: P.O. Box 1836, Lowell, MA 01853 U.S.A.
E-mail: KKCpressoffice@yahoo.com